**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២៥៥៧ សហវ.ឯក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ១.២២១.៧០២,៤៧ ដុល្លារអាមេរិក សម្រាប់គម្រោងជួសជុលស្តារឡើងវិញ ទំនប់បង្វៀរអន្លង់រុន និងទំនប់បង្វៀរក្តារ ស្ថិតក្នុងខេត្តព្រៃវែង ។

**យោង:** -លិខិតលេខ ១៨៦ សជណ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ។

-លិខិតលេខ ៨៥៨ ធទឧ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹកនិងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាចំនួន ១.២០០.០០០ ដុល្លារអាមេរិក ( មួយលាន ពីរយពាន់ដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និង ឧតុនិយមដើម្បីស្តារឡើងវិញទំនប់បង្វៀរអន្លង់រុន និងទំនប់បង្វៀរក្តារ ស្ថិតក្នុងខេត្តព្រៃវែង សម្រាប់ការងារដូចខាងក្រោម:

-សង់ទំនប់អមសងខាងស្ទឹងក្រាលគ្រួសក្រហមប្រវែង ២.៤០០ ម

-សង់សំណង់បង្ហៀរប្រវែង ០២កន្លែង

-សង់លូស្រោចស្រព ០២កន្លែង

-ជួសជុលសំណង់បង្ហៀរស្ទឹងជោរមួយកន្លែងប្រវែង ២១០ ម

ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 2480-CAM (SF) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចម្លងជូន

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-សាលាខេត្តព្រៃវែង

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រៃវែង

-ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com